# សាកលវិទ្យាល័យ អង្គរខេមរា
# ANGKOR KHEMARA UNIVERSITY

មហាវិទ្យាល័យ
College
វិទ្យាសាស្ត្ររបស់អប់រំ
Science Educat
សិល្បៈ មនុស្សសាស្ត្រ និងភាសា
Arts, Humanities and Languages

ឯកទេស៖ អក្សរសាស្ត្រខ្មែរ
Specialty: Khmer Literature

## មុខវិជ្ជា៖ ប្រវត្តិសិល្បៈ

Art History

## ប្រធានបទ

## “ប្រពៃណីនៃការឡើងអ្នកតាឈើទាលទោល”

Tradition of climbing a lonely tree

**បង្រៀននិងណែនាំដោយ៖ បណ្ឌិត យ៉ាន់ ទិតារតន៍**


**រៀបរៀងដោយនិស្សិតថ្នាក់ ៖ បរិញ្ញាបត្រ**

Witten by Undergraduate Students

**១. ឌី ដានី (ស្រី)**

**២.ឌី ជីវ័ន្ត (ប្រុស)**

**និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៤-១៥ វគ្គទី០១ ឆមាសទី០១ ឆ្នាំទី០៣**

**សាខាពោធិ៍សាត់**


ព.ស២៥៦៧ ឆ្នាំសិក្សា៖២០២៣-២០២៤ គ.ស ២០២៤

# អារម្ភកថា

គ្រប់ប្រទេស ជាតិសាសន៍ទាំងអស់ក្នុងពិភពលោកយើងនេះ សុទ្ធតែមាននៅប្រវត្តិសាស្ត្រ អក្សរសិល្ប៍ វប្បធម៌ ក៏ជាអរិយធម៌ប្រចាំប្រទេសជាតិនីមួយៗ។ ដោយឡែកបើយើងក្រឡេក មកមើលប្រទេសកម្ពុជាយើងដែលជាប្រទេសមួយដែលស្ថិតនៅក្នុងចំណោមតំបន់អាស៊ីអាគ្នេយ៍ ហើយប្រទេសកម្ពុជាយើង គឺជាប្រទេសមួយសម្បូរទៅដោយ ប្រវត្តិសាស្ត្រ វប្បធម៌ និងសិល្បៈ ទំនៀមទម្លាប់ សាសនា ព្រមទាំងអរិយធម៌ជាច្រើនដូចទៅនឹងប្រទេសនានាដែរ។ ពិសេសនោះបើយើងបង្វែរចក្ខុទៅមើលសម័យកាលពេលវេលាកន្លងទៅរាប់សតវត្សនោះ ពិតណាស់ចាស់បុរាណយើងតែងមានជំនឿជឿទៅលើកម្លាំងក្រៅខ្លួន ឬពឹងលើកម្លាំងធម្មជាតិ ដែលមានការគោរពអ្នកតាចាស់ស្រុក អរក្ស ទេវតា ជំនាងផ្ទះជាដើម។ ទន្ទឹមនឹងដូចដែលបានរៀបរាប់ខាងលើហើយ ទើបខ្ញុំបាទ នាងខ្ញុំបានលើយកជំនឿរបស់អ្នកភូមិផ្ទះរុង ដែលគោរពបូជាលើ**អ្នកតាឈើទាលទោល** យកមកចងក្រងធ្វើជាឯកសារទុកជាប្រយោជន៍ទៅថ្ងៃមុខ។ យ៉ាងណាមិញស្នាដៃដ៏តូចមួយនេះគឺគ្រាន់តែជួយបំពេញចំណេះដឹងបន្ថែមដើម្បីឱ្យបានដឹងបានស្គាល់នឹងទទួលចំណេះដឹងខ្លះៗប៉ុណ្ណោះវាមិនមែនជាឯកសារជាគោលឡើយ។ មួយវិញទៀតជាការ លើកស្ទួយ លើកតម្កើន និងរក្សាទំនៀមទម្លាប់ប្រពៃណីរបស់ដូនតាខ្មែរយើងតាំងពីបុរាណកាលថែមទៀងផង។

ជាចុងបញ្ចប់ខ្ញុំបាទនាងខ្ញុំសូមខន្តីអភ័យទោសរាល់កំហុសខុសឆ្គងដោយអចេតនាក្នុងការសរសេរកិច្ចការស្រាវជ្រាវមួយនេះ។ ទៀតសោត បទពិសោធន៍និងចំណេះដឹងក្នុងការស្រាវជ្រាវឯកសាររបស់ខ្ញុំនៅមានកម្រិតនៅឡើយហេតុនេះហើយ កិច្ចការស្រាវជ្រាវមួយនេះ គឺចៀសមិនផុតឡើយពីកំហុសឆ្គង និងភាពខ្វះខាតឡើយ។ ដូច្នេះហើយក្រុមរបស់ខ្ញុំ សូមស្វាគមន៍យ៉ាងរីករាយ ពីសំណាក់មតិយោបល់និងមតិកែលម្អ ផ្សេងៗពីនិស្សិត ពិសេសអ្នកគ្រូ**យ៉ាន់ វិភារតន៍** ដែលអាចជួយកែលម្អកិច្ចការស្រាវជ្រាវមួយនេះឲ្យកាន់តែមានភាពល្អប្រសើរឡើងថែមមួយកម្រិតទៀត។

*ផ្ទះរុងថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤*

# សេចក្តីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណរគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោក តែងតែណែនាំចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលលោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនូវទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ ក្នុងសង្គមធ្វើឲ្យក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុធី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃ សម្រាប់ជួយខ្លួនឯងគ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងឯកទេស អក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញុំាងឲ្យខ្ញុំបាទ ទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះសាស្ត្រាចារ្យ បណ្ឌិត **យ៉ាន់ ទិត្យារតន៍** ដែលបង្រៀនលើមុខវិជ្ជា*ប្រវត្តិសិល្បៈ* ដែលបានណែនាំកែតម្រូវលើកិច្ចការស្រាវជ្រាវមួយនេះ។

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបាន បន្សល់ស្នាដៃដ៏វិសេសវិសាលសម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# មាតិកា

*ទិដ្ឋភាពទូទៅ

I.សេចក្តីផ្តើម ........................................................................ ទំព័រ ១

II.ប្រវត្តិ........................................................................ ទំព័រ ១-៣

III.ទីតាំងភូមិសាស្រ្ត........................................................................ ទំព័រ ៣-៦

IV.របៀប ឬកិច្ចពិធី ........................................................................ ទំព័រ ៦-៧

៤.១ មុនពេលប្រារព្ធពិធី........................................................

៤.២ ពេលប្រារព្ធពិធី........................................................

៤.៣ ក្រោយចប់ពិធីឡើងអ្នកតា........................................

V.សន្និដ្ឋាន ........................................................................ ទំព័រ ១១

VI.ឯកសារពិគ្រោះ ........................................................................ ទំព័រ ១១

VII.រូបភាព........................................................................ ទំព័រ ១១-១៤

# ទិដ្ឋភាពទូទៅ

## I. សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានវប្បធម៌ អរិយធម៌របស់ខ្លួនតាំងពីយូរលង់ណាស់មកហើយ គឺមានចាប់តាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ ដោយប្រជាជននាសម័យនោះរស់នៅប្រមូលផ្តុំគ្នាជាភូមិតូចឬធំសង់ផ្ទះផុតពីដីនៅតាមមាត់ទឹក ចេះប្រកបមុខរបបចិញ្ចឹមជីវិតដោយធ្វើកសិកម្មដាំដំណាំស្រូវ ពោត និងដំណាំផ្សេងៗ។ ម៉្យាងវិញទៀតប្រជាជនខ្មែរនាសម័យនោះ ចេះផ្សាំងសត្វគោ ជ្រូក មាន់ ឆ្កែ ទា មិនតែប៉ុណ្ណោះចេះបរបាញ់សត្វ នេសាទ បេះផ្លែឈើចិញ្ចឹមជីវិតទៀតផង។ លើសពីនេះទៅទៀត ចំពោះសីលធម៌រស់នៅ មនុស្សពីសម័យបុរាណមានជំនឿលើគុណទោសបុណ្យបាប អំពើល្អអាក្រក់ ចេះគោរពដូនតា អ្នកតាចាស់ស្រុក ដើមឈើធំព្រលឹងខ្មោចជាដើម ដោយពួកគេជឿថាគ្រប់មនុស្សសត្វពេលស្លាប់ទៅហើយ តែងតែមានព្រលឹងទាំងអស់។ លះមកដល់ពេលបច្ចុប្បន្ននេះប្រជាជនខ្មែរយើង ក៏នៅតែរក្សា ទំនៀមទម្លាប់ប្រពៃណីទាំងនោះយ៉ាងខ្ជាប់ខ្ជួន ជាពិសេសគឺមានជំនឿទៅលើអ្នកតាចាស់ស្រុកតែម្តង។

## II. ប្រវត្តិរបស់អ្នកតាទាលតូល

ដោយតាមការសម្ភាសន៍ចំពោះលោក**អ៊ុំស្រី ឆែម ធូយ**[១] ដែលជាចាស់ព្រឹទ្ធាចារ្យនៅភូមិដែលជា ទីតាំងផ្ទាល់និងតាមរយៈលោកគ្រូ **សាន ស្រី** ដែលជានាយកសាលាវិទ្យាល័យកោះស្វាយ បានរៀបរាប់ បានរៀបរាប់ថា ចំពោះជីវប្រវត្តិរបស់ អ្នកតាទាលទោល លោកតាទោល កាលពីដើមឡើយ លោកជាគ្រូពេទ្យ បុរាណមួយរូបដែលចេះស្តោះផ្លុំ ចំពោះការថ្លោះ ក្រិច បាក់ឆ្អឹងឆ្អែងកូនក្មេងយំ ចេះដោះអំពើ ចេះព្យា បាលរោគឬជំងឺផ្សេងៗយ៉ាងពូកែស័ក្តសិទ្ធ ដោយសម័យនោះផ្នែកវិជ្ជសាស្ត្រមិនទាន់កើតឡើង ដោយពុំទាន់មានពេទ្យសម្រាប់ព្យាបាលជំងឺឡើយ គឺមានតែគ្រូបុរាណសម្រាប់ព្យាបាលជំងឺ។ដូចនេះ បើមាននរណាម្នាក់កើតមាន ជំងឺឈឺ ដោយរោគផ្សេងៗនោះ គឺតែងតែមករកលោកតាតូល ឱ្យព្យាបាលឱ្យជានិច្ច ហើយក្រោយពីព្យាបាលរួចគឺតែងតែជាសះស្បើយដូចបំណងប្រាថ្នា លុះយូរៗទៅកេរ្តិ៍ឈ្មោះរបស់លោកបានល្បីសុះសាយ ពីភូមិមួយទៅភូមិមួយៗ ដែលជាហេតុធ្វើឱ្យ ប្រជាជន នៅភូមិផ្ទះរុងទាំងមូលមានជំនឿគ្រប់ៗគ្នាលើរូបគាត់។

---

[១] *អ៊ុំស្រី ឆែម ធូយ ជាចាស់ព្រឹទ្ធាចារ្យនៅភូមិផ្ទះរុង ឃុំផ្ទះរុង ស្រុកតាលោសែន ជ័យ ខេត្តពោធិ៍សាត់។*

[២] *លោកគ្រូសាន ស្រី មាន ជានាយកសាលាវិទ្យាល័យកោះស្វាយក្នុងឃុំផ្ទះរុង ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់។*

ហើយបើសមាជិកគ្រួសារណាមាន ជំងឺ គឺតែងតែមករកលោកតាឱ្យព្យាបាលគ្រប់ៗគ្នា។ លុះក្រោយពេលដែលលោកតា ទទួលមរណភាព ទៅប្រជាជននៅតែមានជំនឿថាព្រលឹងរបស់លោកតារឹទ្ធិតែខ្លាំងពូកែ ដោយប្រជាជននៅតែនាំគ្នា គោរព ហើយម៉្យាងវិញទៀតប្រសិនបើប្រជាជនមានបញ្ហា គ្រោះអាសន្នក្នុងជីវិតគឺតែងតែទៅបន់ស្រន់ ជានិច្ច ហើយក្រោយពីបន់ស្រន់រួចមកឃើញថាសមដូចបំណងប្រាថ្នារបស់ខ្លួននៅពេលនោះហើយ ទើបប្រជាជនបានឯកភាពគ្នាសាងសង់ខ្ទមនៅក្បែរដើមឈើទាលមួយដើម្បីថ្វាយដល់លោកតា នៅក្បែរមាត់បឹងព្រះពន្លៃ ហើយខ្ទមរបស់លោកតាគឺបន្សល់មកដល់សព្វថ្ងៃ សម្រាប់ជាទីសក្ការៈ គោរពបូជារបស់ប្រជាជនដែលគេនិយមហៅថា **លោកតាឈើទាលទោល**[៣] រហូតមកដល់បច្ចុប្បន្ន។



*(ខ្ទមលោកតាទាលតូល)*

[៣] ***លោកតាឈើទាលទោល*** *ជាឈ្មោះដែលអ្នកស្រុកហៅពីបុរាណមក។*

បន្ថែមលើសពីនេះទៀតនោះក៏មានមតិរបស់អ្នកស្រុកភូមិនៅក្នុងតំបន់នៃបឹងព្រះពន្លៃមានតំណាលថាដែលរៀបរាប់ពីប្រវត្តិរបស់លោកតាថា តាំងពីដើមឡើយនៅក្នុងបឹងព្រះពន្លៃ គឺមានសរសេរឈើដ៏ធំមួយដើម ដែលដូចដើមឈើទាលដាំក្នុងកណ្តាលទឹកបឹង និងមានអ្នកតាមួយរូបដែលជាអ្នកកាន់ការពារគឺឈ្មោះអ្នកតាទាលទោល។[៤]





[៤] *ដកស្រង់ចេញពី សារព័ត៌មានមេគង្គប៉ុស្តិ៍*

## III. ទីតាំងភូមិសាស្ត្រ

ចំពោះអាស្រមរបស់លោកតាទាលទោល គឺមានទីតាំងស្ថិតនៅត្រើយខាងជើង នៃបឹងព្រះពន្លៃ ឃុំផ្ទះរុង ស្រុកតាលោសែនជ័យ[៥] ខេត្តពោធិ៍សាត់។






*(ទាំងនេះជារូបភាពគឺជាទីតាំងខ្ទមរបស់លោកតាទាលតួលដែលទាញពីផែនទី)*

[៥] *ស្រុកតាលោសែនជ័យបង្កើតឡើងនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយការកាត់ឃុំពីរគឺ ឃុំតាលោ នៃស្រុកបាកាន និងឃុំផ្ទះរុង នៃស្រុកភ្នំក្រវាញ។*

*យោងតាមអនុក្រឹត្យលេខ ០៧ អនក្រ.បក។*

គួរបញ្ជាក់ដែរថាតំបន់បឹងព្រះពន្លៃ គឺសម្បូរទៅដោយសត្វស្លាបព្រៃចម្រុះរាប់ពាន់ក្បាល និងមច្ឆាជាតិក៏ច្រើនមហិមានៅក្នុងអាងព្រះពន្លៃនេះ ដែលអាចឱ្យភ្ញៀវទេសចរណ៍មកទស្សនាសកម្មភាពដ៏រស់រវើកនៃហ្វូងសត្វស្លាប នាពេលព្រឹកព្រលឹមរហូតដល់ថ្ងៃរះកម្ពស់ដើមត្នោត និងពេលថ្ងៃរៀបលិច។








*( បង្គោលព្រំប្រទល់បឹងព្រះពន្លៃ )*

## IV.**របៀប ឬកិច្ចពិធី**

ប្រពៃណីបុណ្យឡើងលោកតាឈើទាលទោលដែលជាទំនៀមទម្លាប់របស់អ្នកភូមិផ្ទះរុង ជារៀងរាល់ឆ្នាំអ្នកភូមិតែងនាំគ្នាប្រារព្ធធ្វើពិធីនេះឡើងនៅបរិវេនបឹងព្រះពន្លៃ សិត្ថក្នុងភូមិផ្ទះរុង ឃុំផ្ទះរុង ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់។



ជារៀងរាល់ឆ្នាំថ្ងៃ៣ ខែមាឃ អ្នកភូមិតែងប្រមូលគ្នា រៀបចំទំនៀមទម្លាប់ឡើង អ្នកតាទាលទោលនេះដើម្បីរក្សាទំនៀមទម្លាប់ប្រពៃណីបុរាណដែលមានការចូលរួមពីប្រជាជន លោកអាចារ្យ មេភូមិ មេឃុំ ចៅហ្វាយស្រុក ចៅហ្វាយខេត្តជាដើម ដែលបង្ហាញពីការរក្សា ជំនឿ អបីដែលបំបាត់បានទោះបីសម័យកាលនេះមានការរីកចម្រើនក្ដី។



## ៤.១ មុនពេលប្រារព្ធពិធី

អ្នកផ្តួចផ្តើមតែងដើរអញ្ជើញ ប្រកាសតាមរយៈផ្ទាល់មាត់ ឬសំបុត្រប្រាប់ដល់ប្រជាជន និងអាជ្ញាធរដែលដី ដើម្បីចូលរួម ក្នុងពិធីឡើងអ្នកតា។



## ៤.២ ពេលប្រារព្ធពិធី

មុនពេលការចាប់ផ្តើមឡើងអ្នកតា យើងឃើញមានការតម្លើងរោងប្រៀបដូចជាពិធីការបុណ្យពិធីបុណ្យរបស់អ្នកស្រុកដែរ។ហើយមានរៀបចំធ្វើបាយសី រូបចាបធ្វើពីស្លឹកដូង និងសម្ភារៈផ្សេងៗដើម្បីត្រៀម ធ្វើពីធីសូត្យមុនពេលល្ងាចដោយមានមនុស្សច្រើនកុះករចូលរួម។



លុះដល់ពេលល្ងាច មានការចូលរួមពីប្រជាជន មន្ត្រីរាជការគ្រប់ថ្នាក់ លោកយាយ លោកតា ដោយមានពិធីសែនក្រុងពលី និងសូត្រមន្តព្រមទាំងបរិភោគអាហារជុំគ្នា។



ការឡើងអ្នកតាឈើទាលទោលគឺ ធ្វើឡើងដើម្បីសុំសេចក្តីសុខ ហើយចំពោះគ្រឿងដណ្តាប់ក្នុងការធ្វើពិធី យើងសង្កេតឃើញមានស្លាធម៌ ទៀនធូប បាយសី ធ្មីផ្កាក្រអូប អំបោះចងដៃ ផ្លែឈើ ភេជ្ជៈ ពិសេសសស្រាស ក្បាលជ្រូក មាន់ស្ងោ២ក្បាល បង្អែម៥ បាយ៥ សម្លរ៥។






*( គ្រឿងថ្វាយ លោកតាទាលទោល )*

ក្នុងរយៈពេល១ឬ២ម៉ោង ក្នុងពិធីនេះគឺគេមានប្រារព្ធការលេងភ្លេងរក្ស និងចូលរូបដែលជាជំនឿពីបុរាណមកជាមួយផងដែរទៀតផង។





លុះព្រឹកឡើងមាននិមន្តព្រះសង្ឃចំនួន ៥០-១០០អង្គ ឆាន់មួយព្រឹក រហូតដល់ថ្ងៃត្រង់គឺមានការរាបបាត ដោយមានការចូលរួមពីប្រជាជន មន្ត្រីរាជការ អាជ្ញធរថែមទៀតផង។

## ៤.៣ ក្រោយចប់ពិធីឡើងអ្នកតា

ក្រោយពីបញ្ចប់ការធ្វើពិធីបុណ្យអ្នកតា រួចប្រជាជនក៏ជួនតែសេចក្ដីសុខ រីកចម្រើនក្នុងរបរការងារ រកស៊ី ជំងឺសង្កាត់មកយ៉ាយីសត្វចិញ្ចឹមក៏ចាកឆ្ងាយផុតទៅ។ ព្រមទាំងមានអំណោយផង

ចំពោះអាកាសធាតុមានភ្លៀងធ្លាក់គ្រប់គ្រាន់សម្រាប់ស្រោចស្រង់ដំណាំប្រជាជនក្នុងតំបន់ដែលធ្វើឱ្យការទទួលបានទិន្នផលកសិកម្មបានយ៉ាងគួរសម។

## V.សន្និដ្ឋាន

ការដែរមានជំនឿលើកម្លាំងក្រៅខ្លួន គឺជាប្រពៃណីទម្លាប់របស់អ្នកស្រុកខ្មែរយើង ដូច្នេះការប្រារព្ធ ពិធីការឡើងអ្នកតាឈើទាលទោលគឺជាផ្នែកមួយ ដែលសម្គាល់អត្តសញ្ញាណរបស់ខ្មែរយើង ដែល ធ្វើការប្រកាន់យ៉ាងខ្ជាប់ខ្ជួន បើទោះបីប្រទេសជាយើងកំពុងតែមានការរីកចម្រើនក៏ដោយ

## VI.ឯកសារពិគ្រោះ

សម្រង់ចេញពីៈ

- ការបទសម្ភាសន៍របស់អ៊ុំស្រី ឆែម ធូយ និងលោកគ្រូ សាន ស្រី

- ការស្រាវជ្រាវតាមបណ្ដាញសង្គម។

# រូបមួយចំនួនអំពើអ្នកតាឈើទាលទោល





















